# ចាប់បើកទទួលពាក្យរើសតួសម្តែង
# សម្រាប់ស្នាដៃល្ខោននិយាយ «ចាប៉ី»

និពន្ធដោយ លោក សួន សុធារ៉ា

ដឹកនាំដោយ MEETEI Jayanta (មកពី EX-Theatre Taiwan)

ជំនួយការដឹកនាំសម្តែង៖ លោក សួង សុភ័ក្ត្រ

អត្ថបទរឿង «ចាប៉ី» ត្រូវបានតាក់តែង និងកែសម្រួលក្រោមកម្មវិធីសិក្ខាសាលាជាបន្តបន្ទាប់មួយរៀបចំឡើងដោយអង្គការសិល្បៈខ្មែរអមតៈ។ ហើយវគ្គមួយនៃផ្ទៃរឿងនេះ នឹងត្រូវសម្តែងជូនជាសាធារណៈនៅខែវិច្ឆិកា ឆ្នាំ ២០១៩ សម្រាប់កម្មវិធីមហោស្រពសិល្បៈដើម្បីសន្តិភាពរបស់យើង ហើយសាច់រឿងទាំងមូលនឹងត្រូវដំឡើងជាស្នាដៃល្ខោនពេញលេញនៅឆ្នាំ២០២០ ក្រោមកិច្ចសហការរវាងកម្ពុជា និងតៃវ៉ាន់។ (ព័ត៌មានបន្ថែម នឹងបញ្ជាក់ជូនតាមក្រោយ)

ដូច្នេះ យើងកំពុងជ្រើសរើសសិល្បករប្រកបដោយទេពកោសល្យចំនួន ២រូប សម្រាប់ស្នាដៃមួយនេះ៖

**១.** **<u>តួអង្គ ចារ៉ា៖ ជាតួឯក ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម</u>**

- ភេទប្រុស អាយុពី១៨ ដល់ ៣០ឆ្នាំ
- មានបទពិសោធន៍សម្តែងលើឆាក
- ចេះដាក់អារម្មណ៍ និងមនោសញ្ចេតនាបានល្អ និងស្គាល់បច្ចេកទេសសម្តែងល្ខោនបានច្រើន (ការប្រើសម្លេង និងពាក្យពេចន៍បានល្អ និងច្បាស់លាស់ ....)
- បើចេះលេងចាប៉ី និងចេះច្រៀង កាន់តែប្រសើរ
- បើចេះភាសាអង់គ្លេស កាន់តែប្រសើរ

**២.** **<u>អ្នកដេញចម្រៀងចាប៉ី</u>**

- ភេទប្រុស អាយុពី ៣០ ដល់ ៥០ឆ្នាំ
- អាចលេងចាប៉ី និងច្រៀងបំភ្លែភ្លាមៗជាមួយទស្សនិកជន
- បើមានបទពិសោធន៍សម្តែង កាន់តែប្រសើរ
- បើចេះភាសាអង់គ្លេស កាន់តែប្រសើរ

សិល្បៈខ្មែរអមតៈ

លេខទូរស័ព្ទ +855 (0)23 986 032
info@cambodianlivingarts.org
www.cambodianlivingarts.org

ផ្ទះលេខ១២៨G៩ មហាវិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

228 Park Ave S #49331, New York, NY 10003, សហរដ្ឋអាមេរិក

## អំពីតារាងពេលវេលា និងអត្ថប្រយោជន៍

- ការហាត់សមសម្រាប់បេក្ខជនជាប់ឈ្មោះ នឹងប្រព្រឹត្តិទៅពីថ្ងៃទី២៦-៣០ ខែសីហា ឆ្នាំ២០១៩ ជារៀងរាល់ថ្ងៃ ពីម៉ោង ៨.៣០ព្រឹក ដល់ម៉ោង ១២ថ្ងៃត្រង់ និងពីម៉ោង ២រសៀល ដល់ ម៉ោង៥ល្ងាច នៅភ្នំពេញ ដោយទទួលបានថ្លៃហាត់សម ១០ដុល្លារ/ថ្ងៃ។ សម្រាប់ការសម្តែង នឹងទទួលបាន ១០០ ដុល្លារ។
- នៅខែតុលា នឹងមានការហាត់សមចុងក្រោយរយៈពេល ៣ថ្ងៃ ដោយទទួលបានថ្លៃហាត់សម ១០ ដុល្លារ/ថ្ងៃ។
- រយៈពេលសម្តែង ១៥នាទី នៅមហោស្រពសិល្បៈដើម្បីសន្តិភាព ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅភ្នំពេញ។
- ឱកាសហ្វឹកហាត់បន្ថែមនៅតៃវ៉ាន់ក្នុងឆ្នាំ២០២០ (នឹងបញ្ជាក់ជូនតាមក្រោយ)។
- ឱកាសចូលរួមសម្តែងក្នុងស្នាដៃពេញលេញ នៅខែកក្កដា ឆ្នាំ២០២០ នៅភ្នំពេញ (នឹងបញ្ជាក់ជូនតាមក្រោយ)។

## ការធ្វើតេស្តសមត្ថភាព និងការប្រកាសលទ្ធផល

- កាលបរិច្ឆេទធ្វើតេស្ត៖ ថ្ងៃទី២៦ ខែកក្កដា ពីម៉ោង៩ព្រឹក ដល់ ១២ថ្ងៃត្រង់ នៅការិយាល័យអង្គការសិល្បៈខ្មែរអមតៈ (ពេលវេលាជាក់ស្តែង នឹងជូនដំណឹងដល់បេក្ខជនជាប់វគ្គជម្រុះដាក់ពាក្យ)
- សម្រាប់តួសម្តែង៖ សូមទន្ទេញឲ្យស្ទាត់ និងសម្តែងតាមអត្ថបទរឿងដូចមានភ្ជាប់ជូនខាងក្រោម ដោយគ្មានកាន់អត្ថបទរឿងក្នុងដៃ (និងប្រសិនបើអាច សូមរៀបចំចម្រៀងចាប៉ីដងវែង)។
- សម្រាប់តួច្រៀង៖ សូមត្រៀមចម្រៀងជាទម្រង់ចម្រៀងចាប៉ីដងវែង (ផាត់ជាយ ឬសំពោង ។ល។) និង (ប្រសិនបើអាចត្រៀមសម្តែងតាមអត្ថបទរឿងដូចមានភ្ជាប់ជូនខាងក្រោម ដោយគ្មានកាន់អត្ថបទរឿងក្នុងដៃ)។
- លទ្ធផលនឹងត្រូវប្រកាសថ្ងៃទី២ ខែសីហា។

## កាលបរិច្ឆេទ

បេក្ខជនដែលមានចំណាប់អារម្មណ៍ចូលរួមសម្តែង សូមប្រញាប់ផ្ញើពាក្យមកអាសយដ្ឋាន ផ្ទះលេខ ១២៨-G9 មហាវិថី សុធារស ឬអ៊ីម៉ែល chandaly@cambodianlivingarts.org ត្រឹមថ្ងៃទី **២២ ខែកក្កដា ម៉ោង ៥.៣០ ល្ងាច**។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកលេខ 086-895-556។ អាចទាញយកពាក្យទៅបំពេញ និងអត្ថបទរឿង ពី www.cambodianlivingarts.org ឬមកយកដោយផ្ទាល់នៅការិយាល័យសិល្បៈខ្មែរអមតៈ។ បេក្ខជនដែលឆ្លងផុតវគ្គជម្រុះ ត្រៀមចូលវគ្គធ្វើតេស្តសមត្ថភាព នឹងទទួលបានការជូនដំណឹង។

**១. អត្ថបទសម្រាប់ការធ្វើតេស្តសម្តែងជាតួអង្គ ថារ៉ា**

តួអង្គថារ៉ា៖ នេះគឺជាកេរតែមួយគត់ដែលលោកតារបស់ខ្ញុំបានបន្សល់ទុកឱ្យខ្ញុំ។ចាប៉ីនេះហើយដែលលោកតារបស់ខ្ញុំប្រើវាដើម្បីដេញច្រៀងនូវទំនុកច្រៀងជាច្រើនប្រកបដោតអត្ថន័យអប់រំដ៏ក្រអួនក្រអៅ។ លោកតាមរបស់ខ្ញុំតែងតែនាំវាទៅជាមួយគ្រប់ទីកន្លែងដែលគាត់បានទៅដល់ ហើយគាត់ក៏មិនដែលទុកវាឱ្យឃ្លាតឆ្ងាយពីគាត់នោះដែរ។ នៅចាំកាលណោះ ខ្ញុំទើបតែអាយុប្រាំឬប្រាំមួយឆ្នាំប៉ុណ្ណោះ ប៉ុន្តែនៅក្នុងចិត្តខ្ញុំពិតជាកោតសរសើរ និងពេញចិត្តនូវទេពកោសល្យរបស់គាត់យ៉ាងចម្លែក។ លោកតាតែងតែច្រៀងចាប៉ីឱ្យក្រុមគ្រួសារខ្ញុំស្តាប់ មិនថាពេលគាត់សប្បាយចិត្ត ឬមានទុក្ខកង្វល់ខ្វាយខ្វល់ក្នុងចិត្តយ៉ាងណាក៏ដោយ។ សិល្បៈតន្ត្រីចាប៉ី និងចម្រៀងចាប៉ីគឺជាមធ្យោបាយដែលលោកតារបស់ខ្ញុំប្រើប្រាស់ដើម្បីសន្ទនាជាមួយខ្លួនគាត់ អ្នកនៅជុំវិញគាត់ និងពិភពខាងក្រៅ។ ខ្ញុំនៅចាំបាន នៅពេលមួយនោះ លោកយាយរបស់ខ្ញុំបាននិយាយទៅកាន់លោកតាថា៖ *ប្រពន្ធរបស់តាប៉ិឯងគឺជាចាប៉ី មិនមែនខ្ញុំនេះទេ ខ្ញុំឃតែពេលណាមានចាប៉ីនៅជាប់ដៃ តាប៉ិឯងមើលមិនឃើញខ្ញុំនៅក្នុងកែវភ្នែកសោះ គិតៗតែពីចាប៉ី។ និយាយតាមត្រង់ទៅ បើខ្ញុំជាចាប៉ីនេះវិញប្រហែលជាល្អជាងធ្វើជាប្រពន្ធរបស់តាឯង។ ហ្អើយ! មិនដឹងថាបុណ្យអីទេ ដែលបណ្តាលឱ្យចិត្តខ្ញុំព្រមរៀបការជាមួយ។* នៅពេលដែលស្តាប់ជីដូនខ្ញុំនិយាយចប់ លោកតាចាប់ផ្តើមកាន់ចាប៉ី និងដេញច្រៀងនូវទំនុកច្រៀងដែលធ្វើឱ្យលោកយាយរបស់ខ្ញុំស្តាប់ទៅអស់សំណើចជាខ្លាំង។

**២. បទចម្រៀងចាប៉ីសម្រាប់តេស្តសមត្ថភាព៖** សូមត្រៀមបទចម្រៀង ១ ឬ២បទ ជាទម្រង់ចម្រៀងចាប៉ី (ឧទាហរណ៍ ផាត់ជាយ ឬសំពោង ។ល។)